**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ: ០០២/២២ ក.ប/ប្រ.ក.ខ.ល

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យប្រើគោលការណ៍ប្រតិបត្តិស្តង់ដាស្តីពីដំណើរការ និងការគ្រប់គ្រងរោងចក្រ សហគ្រាសតាមគន្លងប្រក្រតីភាពថ្មីក្នុងបរិបទនៃជំងឺកូវីដ-១៩

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការរដ្ឋបាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៨៥ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

## សម្រេច

**ប្រការ១ ._**

ត្រូវបានដាក់ឱ្យប្រើគោលការណ៍ប្រតិបត្តិស្តង់ដាស្តីពីដំណើរការ និងការគ្រប់គ្រងរោងចក្រ សហគ្រាស តាមគន្លងប្រក្រតីភាពថ្មីក្នុងបរិបទនៃជំងឺកូវីដ-១៩ ដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ ក្នុងគោលបំណងចូលរួមការពារសុវត្ថិភាពនិងសុខភាពការងាររបស់កម្មករនិយោជិត និងរក្សាស្ថិរភាពអាជីវកម្ម/ផលិតកម្មរបស់រោងចក្រ សហគ្រាស ក៏ដូចជាចូលរួមទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅតាមរោងចក្រ សហគ្រាស។

**ប្រការ២ ._**

ម្ចាស់ ឬនាយករោងចក្រ សហគ្រាស មានកាតព្វកិច្ចចូលរួមអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដានេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ប្រការ៣ ._**

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ ._**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ អគ្គនាយកបេឡាជាតិសន្តិសុខសង្គម ប្រធាននាយកដ្ឋានអធិការកិច្ចការងារ ប្រធាននាយកដ្ឋានពេទ្យការងារ ប្រធាននាយកដ្ឋានវិវាទការងារ ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ២កើត ខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ មករា ឆ្នាំ២០២២

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល**:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គណៈប្រចាំការនៃ គ.ប.ក.
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# គោលការណ៍ប្រតិបត្តិស្តង់ដា
# ស្តីពី
# ដំណើរការ និងការគ្រប់គ្រងរោងចក្រ សហគ្រាស
# តាមគន្លងប្រក្រតីភាពថ្មីក្នុងបរិបទនៃជំងឺកូវីដ-១៩

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# មាតិកា


**ក. សេចក្ដីផ្ដើម** ........ 1

**ខ. យន្តការដំណើរការ និងការគ្រប់គ្រង** ........ 2

១. ភារកិច្ចរបស់និយោជក ........ 2

១.១. បង្កើតក្រុមការងារសុវត្ថិភាព និងសុខភាពការងារប្រចាំរោងចក្រ សហគ្រាស ........ 2

១.២. បណ្ដុះបណ្ដាល និងផ្ដល់ព័ត៌មានអប់រំអំពីសុខភាពដល់កម្មករនិយោជិត ........ 2

១.៣. ត្រៀមរៀបចំយន្តការចាំបាច់នានាផ្សេងទៀតតាមការណែនាំរបស់រាជរដ្ឋាភិបាល ........ 3

២. ភារកិច្ចរបស់ក្រុមការងារសុវត្ថិភាព និងសុខភាពការងារប្រចាំរោងចក្រ សហគ្រាស ........ 3

៣. ភារកិច្ចរបស់កម្មករនិយោជិត ........ 4

**គ. វិធានការដំណើរការការងារតាមគន្លងប្រក្រតីភាពថ្មី** ........ 5

១. មុនចាប់ផ្ដើមដំណើរការការងារប្រចាំថ្ងៃ ........ 5

១.១. រៀបចំកន្លែងការងារឱ្យមានបរិយាកាសស្អាតល្អ និងមានអនាម័យ ........ 5

១.២. ផ្ដល់សម្ភារការពារជំងឺឆ្លងផ្សេងៗ ........ 6

១.៣. រៀបចំប៉ុស្ដិ៍ត្រួតពិនិត្យនៅច្រកទ្វារចេញ-ចូលរោងចក្រ សហគ្រាស ........ 6

២. អំឡុងពេលដំណើរការការងារប្រចាំថ្ងៃ ........ 6

២.១. រក្សាគម្លាតសុវត្ថិភាពបុគ្គលនៅកន្លែងធ្វើការ ........ 6

២.២. កាត់បន្ថយការប្រមូលផ្ដុំកម្មករនិយោជិត ........ 7

២.៣. កាត់បន្ថយការប៉ះពាល់គ្នាដោយផ្ទាល់នៅពេលប្រាស្រ័យទាក់ទងនៅកន្លែងធ្វើការ ........ 7

២.៤. លាងសម្អាតដៃ និងការធ្វើអនាម័យខ្លួនប្រាណ ........ 8

៣. ក្រោយបញ្ចប់ដំណើរការការងារប្រចាំថ្ងៃ ........ 8

៣.១. ធ្វើអនាម័យ និងបាញ់ថ្នាំសម្លាប់មេរោគនៅកន្លែងធ្វើការ និងកន្លែងប្រើប្រាស់រួមគ្នា ........ 8

៣.២. តាមដានសុខភាពកម្មករនិយោជិត ........ 9

៤. ការគ្រប់គ្រងករណីវិជ្ជមានកូវីដ-១៩ ........ 9

**ឃ. ការវាយតម្លៃហានិភ័យ** ........ 10

**ខ. យន្តការអធិការកិច្ច ត្រួតពិនិត្យតាមដាន និងវាយតម្លៃ** ........ 10

ឧបសម្ព័ន្ធទី១៖ គំរូសេចក្ដីសម្រេចស្ដីពីការបង្កើតក្រុមការងារសុវត្ថិភាព និងសុខភាពការងារប្រចាំរោងចក្រ សហគ្រាស

ឧបសម្ព័ន្ធទី២៖ របាយការណ៍វាយតម្លៃប្រចាំខែស្ដីពីស្ថានភាពសុវត្ថិភាព និងសុខភាពការងារនៃកម្មករនិយោជិតនៅក្នុងរោងចក្រ សហគ្រាស

ឧបសម្ព័ន្ធទី៣៖ បញ្ជីស្វ័យត្រួតពិនិត្យអំពីសកម្មភាពពង្រឹងលក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារនៅតាមរោងចក្រ សហគ្រាស

## ក. សេចក្តីផ្តើម

ក្នុងរយៈពេលជិត ២ឆ្នាំ នៃការរីករាលដាលជំងឺកូវីដ-១៩ កន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជាបាន អនុវត្តនូវយុទ្ធសាស្រ្ត វិធានការរដ្ឋបាល និងសុខាភិបាលគ្រប់ជ្រុងជ្រោយប្រកបដោយស្មារតីបុរេសកម្មខ្ពស់ ដោយបានកំណត់យកការចាក់វ៉ាក់សាំងកូវីដ-១៩ ជា **វិធានការយុទ្ធសាស្រ្តគន្លឹះ** សំដៅជួយសង្គ្រោះជីវិត និង ការពារសុខភាពជូនប្រជាពលរដ្ឋនិងកម្មករនិយោជិត និងបង្កើតភាពស៊ាំក្នុងសហគមន៍រឹងមាំពិតប្រាកដមួយ ក៏ដូចជាវិធានការអន្តរាគមន៍ជាច្រើន សំដៅជួយរក្សាលំនឹងធុរកិច្ច និងជីវភាពរស់នៅរបស់ប្រជាជន ជាពិសេស កម្មករនិយោជិត គ្រួសារក្រីក្រ និងជនងាយរងគ្រោះដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរពីការរីករាលដាល ជំងឺកូវីដ-១៩។ ជាក់ស្តែង រាជរដ្ឋាភិបាលបានខិតខំស្វះស្វែងរកវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដើម្បីចាក់ជូន ប្រជាពលរដ្ឋ និងកម្មករនិយោជិតដោយឥតគិតថ្លៃ តាមយុទ្ធសាស្រ្ត "ផ្ការីក" ដែលគិតត្រឹមថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២១ នេះ កម្ពុជាបានក្លាយជាប្រទេសដែលមានអត្រាចាក់វ៉ាក់សាំងខ្ពស់ ដោយបានចាក់វ៉ាក់សាំង ជូន ប្រជាពលរដ្ឋបានប្រមាណ ៨៧% នៃចំនួនប្រជាជនក្នុងប្រទេសសរុបចំនួន ១៦លាននាក់ ខណៈពេល ដែលការចាក់វ៉ាក់សាំងដូសជំរុញបាននិងកំពុងបន្តជាប្រក្រតី។ ជាមួយនឹងជោគជ័យក្នុងការចាក់វ៉ាក់សាំង និងការគ្រប់គ្រងបាននូវការរីករាលដាលជំងឺកូវីដ-១៩ ក៏ដូចជាការធូរស្រាលនៃការរីករាលដាលជំងឺកូវីដ-១៩ នៅក្នុងតំបន់ និងជាសកល រាជរដ្ឋាភិបាលបានសម្រេចបើកឡើងវិញជាជំហានៗនូវសកម្មភាពសង្គម-សេដ្ឋកិច្ច គ្រប់ផ្នែក និងគ្រប់វិស័យ និងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ **ក្នុងការរស់នៅជាមួយមេរោគកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី។**

ដើម្បីបន្តចូលរួមទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ជាពិសេសរក្សាស្ថិរភាពការងារ និង លំនឹងផលិតកម្ម/អាជីវកម្មរបស់រោងចក្រ សហគ្រាសដែលបើកដំណើរការតាមគន្លងប្រក្រតីភាពថ្មី ក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈក៏បានខិតខំដាក់ចេញនូវវិធានការបន្ថែមនានា និងសេចក្តីណែនាំជាបន្ត បន្ទាប់ ដើម្បីធានានូវសុវត្ថិភាព និងសុខភាពការងាររបស់កម្មករនិយោជិតនៅកន្លែងធ្វើការ។ ជាមួយគ្នានេះ ដើម្បីចូលរួម **ស្តារនិងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា តាមគន្លងប្រក្រតីភាពថ្មី** ក្រសួងបានរៀបចំគោលការណ៍ ប្រតិបត្តិស្តង់ដាស្តីពីដំណើរការ និងការគ្រប់គ្រងរោងចក្រ សហគ្រាសតាមគន្លងប្រក្រតីភាពថ្មីក្នុងបរិបទនៃ ជំងឺកូវីដ-១៩ ដោយបានកំណត់យន្តការដំណើរការ និងការគ្រប់គ្រង វិធានការដំណើរការការងារ ការវាយ តម្លៃហានិភ័យ និងមានយន្តការច្បាស់លាស់ក្នុងការធ្វើអធិការកិច្ច ត្រួតពិនិត្យតាមដាន និងវាយតម្លៃតាម រយៈរបាយការណ៍វាយតម្លៃប្រចាំខែស្តីពីស្ថានភាពសុវត្ថិភាព និងសុខភាពការងារនៃកម្មករនិយោជិត និង បញ្ជីស្វ័យត្រួតពិនិត្យអំពីសកម្មភាពពង្រឹងលក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារ ក្នុងគោលបំណងអាច ធានាបាននូវការបង្ការ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ព្រមទាំងអាចធានាបាននូវនិរន្តរភាព ប្រវ៉ាក់ផលិតកម្ម/អាជីវកម្មរបស់រោងចក្រ សហគ្រាស ក៏ដូចជាស្ថិរភាពការងារនិងប្រាក់ចំណូលរបស់កម្មករ និយោជិតផងដែរ។

## ខ. យន្តការដំណើរការ និងការគ្រប់គ្រង

### ១. ភារកិច្ចរបស់និយោជក

#### ១.១. បង្កើតក្រុមការងារសុវត្ថិភាព និងសុខភាពការងារប្រចាំរោងចក្រ សហគ្រាស

- រោងចក្រ សហគ្រាសដែលមានប្រើប្រាស់កម្មករនិយោជិតចាប់ពី ៨ (ប្រាំបី) នាក់ ឡើងទៅ និយោជកមានកាតព្វកិច្ចរៀបចំបង្កើតក្រុមការងារសុវត្ថិភាព និងសុខភាពការងារប្រចាំរោងចក្រ សហគ្រាស (OSH) របស់ខ្លួន ដោយសេចក្តីសម្រេចដែលមានគំរូដូចក្នុងឧបសម្ព័ន្ធទី១ នៃគោលការណ៍ប្រតិបត្តិស្តង់ដានេះ

- ក្រុមការងារសុវត្ថិភាព និងសុខភាពការងារប្រចាំរោងចក្រ សហគ្រាស មានសមាសភាពដូចខាងក្រោម៖

- កម្មករនិយោជិតចាប់ពី ៨ (ប្រាំបី) នាក់ ដល់ ៤៩ (សែសិបប្រាំបួន) នាក់ ត្រូវមានសមាសភាពយ៉ាងតិច ២ (ពីរ) នាក់ ដែលអាចរួមមាន ថ្នាក់ដឹកនាំជាន់ខ្ពស់របស់រោងចក្រ សហគ្រាស ១ (មួយ) រូប និងបុគ្គលិកទទួលបន្ទុកផ្នែកសុវត្ថិភាព និងសុខភាពការងារ (OSH) ១ (មួយ) រូប
- កម្មករនិយោជិតចាប់ពី ៥០ (ហាសិប) នាក់ ដល់ ៦០០ (ប្រាំមួយរយ) នាក់ ត្រូវមានសមាសភាពយ៉ាងតិច ៤ (បួន) នាក់ ដែលអាចរួមមាន ថ្នាក់ដឹកនាំជាន់ខ្ពស់របស់រោងចក្រ សហគ្រាស ១ (មួយ) រូប អ្នកទទួលបន្ទុកផ្នែកគ្រប់គ្រងធនធានមនុស្ស ១ (មួយ) រូប គ្រូពេទ្យសហគ្រាស ១ (មួយ) រូប និងបុគ្គលិកទទួលបន្ទុកផ្នែកសុវត្ថិភាព និងសុខភាពការងារ (OSH) ១ (មួយ) រូប
- កម្មករនិយោជិតចាប់ពី ៦០១ (ប្រាំមួយរយមួយ) នាក់ ឡើងទៅ ត្រូវមានសមាសភាពយ៉ាងតិច ៦ (ប្រាំមួយ) នាក់ ដែលអាចរួមមាន ថ្នាក់ដឹកនាំជាន់ខ្ពស់របស់រោងចក្រ សហគ្រាស ១ (មួយ) រូប អ្នកទទួលបន្ទុកផ្នែកគ្រប់គ្រងធនធានមនុស្ស ១ (មួយ) រូប គ្រូពេទ្យសហគ្រាស ២ (ពីរ) រូប បុគ្គលិកទទួលបន្ទុកផ្នែកសុវត្ថិភាព និងសុខភាពការងារ (OSH) ១ (មួយ) រូប និងតំណាងកម្មករនិយោជិត ១ (មួយ) រូប។

#### ១.២. បណ្តុះបណ្តាល និងផ្តល់ព័ត៌មានអប់រំអំពីសុខភាពដល់កម្មករនិយោជិត

- ណែនាំ អប់រំ និងលើកទឹកចិត្តឱ្យកម្មករនិយោជិតចូលរួមចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ឱ្យបានគ្រប់ៗគ្នា

- រៀបចំឱ្យមានប្រព័ន្ធបំពងសំឡេងនៅតាមអគារធ្វើការ កន្លែងទទួលទានអាហារ និងកន្លែងបិទផ្សាយព័ត៌មានទាក់ទងនឹងវិធានការបង្ការ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងវិធានសុវត្ថិភាព និងសុខភាពការងារផ្សេងៗទៀត។ រាល់ព័ត៌មានស្តីពីសុវត្ថិភាព និងសុខភាពការងារដែលបានផ្សព្វផ្សាយត្រូវមានជាភាសាខ្មែរ

- រៀបចំជាស្លាកសញ្ញាអប់រំសុខភាពស្តីពីវិធានការបង្ការ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងត្រូវដាក់ ឬបិទផ្សព្វផ្សាយនៅកន្លែងធ្វើការដែលអាចឱ្យកម្មករនិយោជិតមើលឃើញច្បាស់

- រៀបចំឱ្យមានការផ្សព្វផ្សាយអំពីវិធានសុវត្ថិភាព និងសុខភាពការងារក្នុងការបង្ការ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដល់ក្រុមការងារសុវត្ថិភាព និងសុខភាពការងារប្រចាំរោងចក្រ សហគ្រាស និងកម្មករនិយោជិត

- ណែនាំកម្មករនិយោជិតពីវិធានសុវត្ថិភាព និងបង្ការខ្លួនពីជំងឺកូវីដ-១៩ មុនពេលទៅធ្វើការ ពេលធ្វើដំណើរ កំឡុងពេលធ្វើការ ក្រោយពេលចេញពីការងារ និងនៅពេលបរិភោគអាហារហាមប្រើប្រាស់ចានស្លាបព្រាររួមគ្នា

- រៀបចំអោយមានបន្ទប់សម្រាករយៈពេលខ្លី និងកន្លែងទទួលទានអាហារដោយមានរបាំងខណ្ឌ និងដាច់ដោយឡែកពីអគារបំពេញការងារ

- ផ្សព្វផ្សាយលើកកម្ពស់ឱ្យមានការយល់ដឹងអំពីសារអប់រំផ្សេងៗ ដូចជា វិធានការ "៣ការពារ និង ៣កុំ" និង "ខ្ញុំថែទាំកន្លែងធ្វើការខ្ញុំឱ្យស្អាតល្អនិងមានអនាម័យ"

- ផ្សព្វផ្សាយដល់កម្មករនិយោជិតនូវព័ត៌មានចាំបាច់ពាក់ព័ន្ធនឹងវិធានការនានារបស់រាជរដ្ឋាភិបាល ក៏ដូចជាអាជ្ញាធរមានសមត្ថកិច្ចដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩

- លើកទឹកចិត្តនិយោជកឱ្យមានការគិតគូរដល់សុខុមាលភាពនៅកន្លែងធ្វើការ តាមរយៈការអនុញ្ញាតឱ្យកម្មករនិយោជិតមានពេលសម្រាកគ្រប់គ្រាន់ រក្សាបាននូវតុល្យភាពរវាងកម្លាំងកាយនិងផ្លូវចិត្ត ហើយនឹងតុល្យភាពរវាងជីវិតនិងការងារ។

### ១.៣. ត្រៀមរៀបចំយន្តការចាំបាច់នានាផ្សេងទៀតតាមការណែនាំរបស់រាជរដ្ឋាភិបាល

ម្ចាស់ ឬនាយករោងចក្រ សហគ្រាស ត្រូវធានាអនុលោមភាពជាមួយនឹងបទប្បញ្ញត្តិច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានពាក់ព័ន្ធនឹងវិធានការការពារកម្មករនិយោជិត បង្ការ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក្នុងគោលបំណងពង្រឹងសុវត្ថិភាព និងសុខភាពការងារនៅកន្លែងធ្វើការ ឱ្យក្លាយជាទីកន្លែងដែលគ្មានហានិភ័យក្នុងការឆ្លងជំងឺកូវីដ-១៩ និងជំងឺឆ្លងនានា ដល់កម្មករនិយោជិតរបស់ខ្លួន និងសាធារណជនទូទៅ។

ម្ចាស់ ឬនាយករោងចក្រ សហគ្រាស ត្រូវរៀបចំយន្តការចាំបាច់ និងចាត់វិធានការប្រុងប្រយ័ត្នផ្សេងៗទៀត តាមការណែនាំរបស់រាជរដ្ឋាភិបាលក្នុងការបង្ការ និងទប់ស្កាត់ជំងឺឆ្លងនានា។

## ២. ភារកិច្ចរបស់ក្រុមការងារសុវត្ថិភាព និងសុខភាពការងារប្រចាំរោងចក្រ សហគ្រាស

- ផ្សព្វផ្សាយជូនកម្មករនិយោជិតទាំងអស់ឱ្យយល់ជ្រួតជ្រាបពីក្រុមការងារនិងសមាសភាពក្រុមការងារ

- រៀបចំផែនការសកម្មភាពស្តីពីការបង្ការ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងផែនការត្រៀមសម្រាប់ឆ្លើយតបពេលមានគ្រោះអាសន្ននៅកន្លែងធ្វើការ

- រៀបចំបន្ទប់ដាច់ដោយឡែកសម្រាប់អ្នកសង្ស័យវិជ្ជមានជំងឺកូវីដ-១៩ ឬពិគ្រោះយោបល់នៅពេលដែលសង្ស័យឆ្លងមេរោគកូវីដ-១៩ ដោយគ្រូពេទ្យសហគ្រាស (គ្រូពេទ្យ គិលានុបដ្ឋាក និងគិលានុបដ្ឋាយិកា ឬឆ្មប) ឬក្រុមការងារទទួលបន្ទុកសុវត្ថិភាព និងសុខភាពការងារប្រចាំរោងចក្រ សហគ្រាស ឬនៅពេលរង់ចាំការមកទទួលទៅកាន់មន្ទីរពេទ្យ

- រៀបចំឱ្យមានសេវាពិគ្រោះយោបល់ផ្លូវចិត្ត និងសុខភាពផ្លូវចិត្តសម្រាប់កម្មករនិយោជិត ប្រសិនបើមានតម្រូវការ

- រៀបចំប្រជុំយ៉ាងតិច ១ (មួយ) ដង ក្នុង ១ (មួយ) ខែ។ ក្នុងករណីចាំបាច់ កិច្ចប្រជុំអាចត្រូវបានធ្វើឡើងជាបន្ទាន់ ដើម្បីដោះស្រាយបញ្ហា ប្រសិនបើមានហេតុការណ៍កើតឡើងនៅផ្នែកណាមួយពាក់ព័ន្ធទៅនឹងការអនុវត្តវិធានសុវត្ថិភាព និងសុខភាពការងារ

- ផ្សព្វផ្សាយអំពីផែនការសកម្មភាព និងការអនុវត្តនូវវិធានការនានាជូនដល់កម្មករនិយោជិត ដើម្បីចូលរួមបង្ការ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងរោងចក្រ សហគ្រាស

- រៀបចំឱ្យមានការបណ្តុះបណ្តាល អប់រំ ផ្សព្វផ្សាយដល់ក្រុមការងារសុវត្ថិភាព និងសុខភាពការងារ និងកម្មករនិយោជិតអំពីវិធានសុវត្ថិភាព និងសុខភាពការងារនៅក្នុងរោងចក្រ សហគ្រាសរបស់ខ្លួន ដោយសហការជាមួយអធិការពេទ្យការងារ

- ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តលក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារនៅក្នុងរោងចក្រ សហគ្រាសដោយរៀបចំជាតារាងកាលវិភាគឱ្យបានត្រឹមត្រូវ

- កែលម្អលក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារ ប្រសិនបើរកឃើញថាអនុវត្តមិនបានត្រឹមត្រូវតាមច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ ឬរកឃើញថាអាចមានហានិភ័យបង្កឱ្យមានគ្រោះថ្នាក់ដល់កម្មករនិយោជិត

- បង្កើតឱ្យមានប្រព័ន្ធផ្សព្វផ្សាយ និងការផ្តល់នូវព័ត៌មានថ្មីៗស្តីពីស្ថានភាពនៃមេរោគកូវីដ-១៩ រួមទាំងចំណេះដឹងចាំបាច់នានាពាក់ព័ន្ធនឹងជំងឺកូវីដ-១៩

- ជួយដល់កម្មករនិយោជិតក្នុងការគ្រប់គ្រង ថែទាំសុខភាពផ្លូវកាយ ផ្លូវចិត្ត ក្នុងករណីមានអាសន្ន ដោយរក្សានូវទំនាក់ទំនងជាប្រចាំតាមរយៈមធ្យោបាយផ្សេងៗ។ ណែនាំ និងផ្សព្វផ្សាយអំពីទម្រង់នៃការរៀបចំការងារ ការរស់នៅ ការហូបចុក ការសម្រាក ការហាត់ប្រាណ និងការរក្សាទំនាក់ទំនងជាមួយគ្រួសារ និងមិត្តភក្តិ ជាដើម

- សិក្សាវាយតម្លៃហានិភ័យ និងរៀបចំវិធានការផ្សេងៗ សម្រាប់ការបើកដំណើរការឡើងវិញនៃរោងចក្រ សហគ្រាស ដែលត្រូវបានផ្អាកដោយវិធានការរដ្ឋបាល ឬដោយការព្យួរសកម្មភាពអាជីវកម្មរបស់ខ្លួន

- អាចលើកសំណើពាក់ព័ន្ធនឹងលក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារមកនាយកដ្ឋានពេទ្យការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីស្នើសុំយោបល់ និងជួយដោះស្រាយ

- រៀបចំរបាយការណ៍វាយតម្លៃអំពីស្ថានភាពសុវត្ថិភាព និងសុខភាពការងារនៃកម្មករនិយោជិតនៅក្នុងរោងចក្រ សហគ្រាស ប្រចាំខែ ដែលមានគំរូដូចក្នុងឧបសម្ព័ន្ធទី២ នៃគោលការណ៍ប្រតិបត្តិស្តង់ដានេះជូននិយោជកទទួលស្គាល់ និងបញ្ជូនមកនាយកដ្ឋានពេទ្យការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ៣. ភារកិច្ចរបស់កម្មករនិយោជិត

- ត្រូវមានទំនួលខុសត្រូវខ្ពស់ក្នុងកាអនុវត្តលក្ខខណ្ឌសុវត្ថិភាព និងសុខភាពរបស់ខ្លួន និងអ្នកដទៃក្នុងការបង្ការការឆ្លងជំងឺកូវីដ-១៩

- ត្រូវប្រុងប្រយ័ត្ន តាមដាន និងអនុវត្តការងារប្រកបដោយសុវត្ថិភាព និងចាត់វិធានការការពារផ្ទាល់ខ្លួនដើម្បីការពារពីការឆ្លងជំងឺនានា ជាពិសេសជំងឺកូវីដ-១៩ និងចូលរួមក្នុងការថែរក្សាសុវត្ថិភាព និងសុខភាពនៅកន្លែងធ្វើការ

- ត្រូវផ្តល់ព័ត៌មាន និងជូនដំណឹងជាបន្ទាន់ដល់រដ្ឋបាលរោងចក្រ សហគ្រាស ក្នុងករណីមានការប៉ះពាល់ផ្ទាល់ជាមួយអ្នកមានវិជ្ជមានកូវីដ-១៩ ឬក្នុងករណីមានអាការសង្ស័យថាមានវិជ្ជមានកូវីដ-១៩។ ការ

ខកខាននៃការផ្តល់ព័ត៌មានទាំងនេះ នឹងចាត់ទុកថាបានល្មើសនឹងបទបញ្ជាផ្ទៃក្នុងរបស់រោងចក្រ សហគ្រាស និងល្មើសនឹងវិធានការសុខាភិបាល

- ផ្តល់សំណាកដល់ក្រុមគ្រូពេទ្យ ដើម្បីវិភាគរកមេរោគកូវីដ-១៩ តាមការកំណត់របស់និយោជក ឬអាជ្ញាធរមានសមត្ថកិច្ច ក្នុងករណីមានអាការសង្ស័យវិជ្ជមានកូវីដ-១៩

- អនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានការ "៣ការពារ" និង"៣កុំ" និងវិធានការសុខាភិបាលនានា

- ចូលរួមវគ្គបណ្តុះបណ្តាល និងវគ្គអប់រំ ស្តីពីលក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារនៅក្នុងរោងចក្រ សហគ្រាសក្នុងបរិបទនៃជំងឺកូវីដ-១៩

- ត្រូវរាយការណ៍ពីគ្រោះថ្នាក់នៅកន្លែងធ្វើការ និងជូនដំណឹងដល់ក្រុមការងារ OSH

- ជូនដំណឹងដល់ក្រុមការងារ OSH របស់រោងចក្រ សហគ្រាស ឬមកនាយកដ្ឋានពេទ្យការងារជាបន្ទាន់ក្នុងករណីពិនិត្យឃើញការខ្វះខាត ឬខកខានអនុវត្តនូវវិធានការសុខាភិបាល។

## គ. វិធានការដំណើរការការងារតាមគន្លងប្រក្រតីភាពថ្មី

ដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការបង្ការ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងរក្សាស្ថិរភាពការងារនិងលំនឹងផលិតកម្ម/អាជីវកម្មរបស់រោងចក្រ សហគ្រាសដែលបើកដំណើរការតាមគន្លងប្រក្រតីភាពថ្មី ទន្ទឹមនឹងការពង្រឹងវិធានការអនុវត្តនូវលក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារតាមបទប្បញ្ញត្តិជាធរមានដែលមានស្រាប់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដាក់ចេញជាគោលការណ៍ប្រតិបត្តិស្តង់ដាស្តីពីដំណើរការ និងការគ្រប់គ្រងរោងចក្រ សហគ្រាសតាមគន្លងប្រក្រតីភាពថ្មីក្នុងបរិបទនៃជំងឺកូវីដ-១៩ នាពេលនេះ។

គោលការណ៍ប្រតិបត្តិស្តង់ដានេះ ណែនាំដល់ម្ចាស់ ឬនាយករោងចក្រ សហគ្រាស និងកម្មករនិយោជិតក្នុងការបំពេញការងារប្រកបដោយសុវត្ថិភាព និងមានសុខភាពល្អនៅក្នុងកន្លែងធ្វើការក្នុងស្ថានភាពរៀនរស់នៅជាមួយមេរោគកូវីដ-១៩ ដោយត្រូវអនុវត្តវិធានមួយចំនួនដូចខាងក្រោម៖

### ១. មុនចាប់ផ្តើមដំណើរការការងារប្រចាំថ្ងៃ

#### ១.១. រៀបចំកន្លែងការងារឱ្យមានបរិយាកាសស្អាតល្អ និងមានអនាម័យ

និយោជកត្រូវ៖

- រៀបចំទីកន្លែងធ្វើការឱ្យមានបរិយាកាសស្អាតល្អ ដើម្បីរក្សាសុខភាពកម្មករនិយោជិត។ បរិយាកាសនេះត្រូវគ្មានភាពកខ្វក់ គ្មានក្លិនដែលនាំឱ្យមានគ្រោះថ្នាក់ ឬនាំឱ្យរំខានដល់ការងារ ដូចជា ចំហាយ ឧស្ម័ន ធូលី ជាដើម

- រៀបចំ និងកែលម្អឱ្យប្រសើរឡើងនូវប្រព័ន្ធបញ្ចេញនិងបញ្ចូលខ្យល់ក្នុងអគារ (ប្រសិនបើមាន) និងជៀសវាងការប្រើប្រាស់កង្ហារផ្ទាល់ខ្លួន

- បើកដំណើរការប្រព័ន្ធបញ្ចេញនិងបញ្ចូលខ្យល់ក្នុងអគារផលិតកម្ម (ប្រសិនបើមាន) ក្នុងរយៈពេលយ៉ាងតិច ៣០ (សាមសិប) នាទី មុនពេលដំណើរការផលិតកម្ម និងថែទាំនិងជួសជុលប្រព័ន្ធបញ្ចេញនិងបញ្ចូលខ្យល់ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស

- បើកចំហទ្វារ បង្អួច ដើម្បីឱ្យមានខ្យល់ធម្មជាតិចេញ-ចូលជាប្រចាំនៅគ្រប់វេនការងារ

- សម្អាតបន្ទប់ ឬកន្លែងការងារដែលមានហានិភ័យខ្ពស់ក្នុងការប្រឈមទៅនឹងការឆ្លងមេរោគ។

**១.២. ផ្ដល់សម្ភារការពារជំងឺឆ្លងផ្សេងៗ**

និយោជកត្រូវ៖

- ផ្ដល់ម៉ាស់ជូនកម្មករនិយោជិតដោយឥតគិតថ្លៃ និងធ្វើការណែនាំពីរបៀបប្រើប្រាស់ម៉ាស់ឱ្យបានត្រឹមត្រូវ និងជាប់ជាប្រចាំនៅពេលបំពេញការងារ និងពេលធ្វើដំណើរទៅផ្ទះនិងកន្លែងធ្វើការ

- ធ្វើការក្រើនរំលឹក និងត្រួតពិនិត្យជាប្រចាំ ដើម្បីធានាថាកម្មករនិយោជិតបានពាក់ម៉ាស់ត្រឹមត្រូវតាមការណែនាំ នៅរាល់ពេលធ្វើការនៅក្នុងរោងចក្រ សហគ្រាស

- ផ្ដល់សម្លៀកបំពាក់វេជ្ជសាស្ត្រដែលអាចការពារតាមកម្រិតហានិភ័យនៃការឆ្លងជំងឺកូវីដ-១៩ ជូនដល់គ្រូពេទ្យសហគ្រាសដែលបម្រើការនៅក្នុងគិលានដ្ឋាន

- រៀបចំឱ្យមានការរក្សាទុក ផ្លាស់ប្ដូរជាទៀងទាត់ ឬបោះចោលម៉ាស់និងសម្លៀកបំពាក់វេជ្ជសាស្ត្រឱ្យបានត្រឹមត្រូវតាមវិធានការសុខាភិបាល ដើម្បីចៀសវាងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

**១.៣. រៀបចំប៉ុស្តិ៍ត្រួតពិនិត្យនៅច្រកទ្វារចេញ-ចូលរោងចក្រ សហគ្រាស**

និយោជកត្រូវ៖

- ត្រូវរៀបចំឱ្យមានក្រុមការងារត្រួតពិនិត្យនៅតាមច្រកចេញ-ចូលរោងចក្រ សហគ្រាស ដើម្បីត្រួតពិនិត្យលើ៖

  - ការវាស់កម្ដៅ
  - ការបាញ់អាល់កុលសម្លាប់មេរោគលើដងខ្លួន និងការសម្អាតដៃ
  - ការស្កេន QR Code ឬការបង្ហាញកាតចាក់វ៉ាក់សាំង
  - ការពាក់ម៉ាស់ និង
  - ការរក្សាគម្លាតសុវត្ថិភាពរាល់កម្មករនិយោជិត និងសាធារណជន ដែលចូលមករោងចក្រ សហគ្រាស

- ក្រុមការងារត្រួតពិនិត្យនៅតាមច្រកចេញ-ចូល មិនត្រូវអនុញ្ញាតឱ្យបុគ្គលទាំងឡាយណាដែលមានរោគសញ្ញាសង្ស័យវិជ្ជមានជំងឺកូវីដ-១៩ និងធ្វើតេស្តរហ័សមានវិជ្ជមានកូវីដ-១៩ ចូលក្នុងទីតាំងផលិតកម្ម/អាជីវកម្មរបស់រោងចក្រ សហគ្រាសឡើយ។

## ២. អំឡុងពេលដំណើរការការងារប្រចាំថ្ងៃ

**២.១. រក្សាគម្លាតសុវត្ថិភាពបុគ្គលនៅកន្លែងធ្វើការ**

និយោជកត្រូវរៀបចំឱ្យមានក្រុមការងារត្រួតពិនិត្យ៖

- ការរក្សាគម្លាតសុវត្ថិភាពបុគ្គលនៅកន្លែងធ្វើការ ស្របតាមការកំណត់របស់វិធានការសុខាភិបាល និងការជំរុញឱ្យកម្មករនិយោជិតពាក់ម៉ាស់ និងប្រកាន់ខ្ជាប់នូវការធ្វើអនាម័យផ្ទាល់ខ្លួនប្រាណជាប់ជាប្រចាំ

- ការរៀបចំដាក់របាំងខណ្ឌ ឬប្រើប្រាស់មធ្យោបាយសមស្របផ្សេងៗ ក្នុងពេលប្រាស្រ័យទាក់ទងជាមួយសាធារណជន ឬពេលហូបបាយជុំគ្នា ក្នុងករណីដែលមិនអាចរក្សាគម្លាតសុវត្ថិភាព

- ការរៀបចំប៉ុស្ដិ៍ការងារនីមួយៗឱ្យបានសមស្របទៅនឹងគម្លាតសុវត្ថិភាពបុគ្គលពីប៉ុស្ដិ៍ការងារមួយទៅប៉ុស្ដិ៍ការងារមួយទៀត ដោយកំណត់អំពីលទ្ធភាពក្នុងការផ្ទុកមនុស្សនៅកន្លែងធ្វើការ និងបរិវេណផ្សេងទៀត ដូចជា សាលប្រជុំ ការិយាល័យ កន្លែងសម្រាប់រៀបចំសិក្ខាសាលា បន្ទប់ទទួលទានអាហារ បន្ទប់ទឹក បន្ទប់ផ្លាស់ប្ដូរសម្លៀកបំពាក់ និងកន្លែងប្រើប្រាស់រួមផ្សេងទៀត ដើម្បីអាចធានាគម្លាតសុវត្ថិភាពបុគ្គលជាអប្បបរមា។

**២.២. កាត់បន្ថយការប្រមូលផ្ដុំកម្មករនិយោជិត**

និយោជកត្រូវ៖

- រៀបចំឱ្យមានរយៈពេលចន្លោះពីវេនមួយទៅវេនមួយទៀត មានលក្ខណៈសមស្រប ក្នុងករណីមានវេនការងារលើសពីមួយវេនក្នុងមួយថ្ងៃ ដើម្បីធ្វើយ៉ាងណាបង្កលក្ខណៈងាយស្រួលឱ្យកម្មករនិយោជិតចេញ-ចូលធ្វើការតាមវេននីមួយៗ មិនមានការប្រជ្រៀតគ្នា និងអាចរក្សាបានគម្លាតសុវត្ថិភាពសមស្របពេលចេញ-ចូលក្នុងរោងចក្រ សហគ្រាស ក្នុងអគារ ឬទីកន្លែងធ្វើការ

- រៀបចំបន្ថែមច្រកចេញ-ចូល ឬបែងចែកពេលវេលាចេញ-ចូលធ្វើការរបស់កម្មករនិយោជិតឱ្យបានសមស្រប ធ្វើយ៉ាងណាកុំឱ្យមានការប្រជ្រៀតគ្នា ដើម្បីរក្សាបាននូវសុវត្ថិភាព និងសុខភាពការងារ

- រៀបចំ និងកំណត់ផ្លូវចេញ-ចូលដែលមានលក្ខណៈជាផ្លូវឯកទិស និងដាក់ស្លាកសញ្ញាសម្គាល់ចរាចរផ្ទៃក្នុង

- រៀបចំទុកដាក់សម្ភារផ្សេងៗឱ្យមានសណ្ដាប់ធ្នាប់ និងធ្វើយ៉ាងណាឱ្យច្រកចេញ-ចូលនីមួយៗមានទំហំទូលាយអាចធ្វើដំណើរបានងាយស្រួល និងរក្សាបានគម្លាតសុវត្ថិភាពបុគ្គល

- ចាត់តាំងអ្នកបើកបរមធ្យោបាយដឹកជញ្ជូនរួមវាស់កម្ដៅអ្នកដំណើរមុនឡើងយានយន្ត និងសម្អាតយានយន្តជាប្រចាំ ដើម្បីធានាបាននូវការបង្ការការចម្លង ឬការឆ្លងមេរោគកូវីដ-១៩ និងត្រួតពិនិត្យកម្មករនិយោជិតដែលប្រើប្រាស់មធ្យោបាយដឹកជញ្ជូនរួមនេះ ត្រូវពាក់ម៉ាស់ជាប់ជានិច្ច និងលាងសម្អាតដៃជាប្រចាំមុនពេលឡើងជិះរថយន្ត និងមិនត្រូវដោះម៉ាស់ ហូបអាហារក្នុងពេលធ្វើដំណើរឡើយ

- រៀបចំវេនកម្មករនិយោជិតនៅតាមទីតាំងប្រើប្រាស់រួម ដូចជាកន្លែងបរិភោគអាហារ អាគារបដ្ឋានកន្លែងសម្រាក និងកន្លែងផ្លាស់ប្ដូរសម្លៀកបំពាក់

- លើកទឹកចិត្តឱ្យកម្មករនិយោជិតវេចខ្ចប់ម្ហូបអាហារ និងជាអាហារឆ្អិនល្អ មានសុវត្ថិភាពមកកន្លែងធ្វើការ។

**២.៣. កាត់បន្ថយការប៉ះពាល់គ្នាដោយផ្ទាល់នៅពេលប្រាស្រ័យទាក់ទងនៅកន្លែងធ្វើការ**

កម្មករនិយោជិតត្រូវ៖

- ជៀសវាង ឬកាត់បន្ថយការប៉ះពាល់គ្នាផ្ទាល់នៅពេលប្រាស្រ័យទាក់ទងគ្នា ដោយត្រូវរក្សាគម្លាតសុវត្ថិភាពសមស្រប និងត្រូវពាក់ម៉ាស់ជាប្រចាំ

- លាងសម្អាតដៃឱ្យបានស្អាត និងជៀសវាង ឬកាត់បន្ថយជាអតិបរមាក្នុងការយកដៃទៅប៉ះភ្នែក ច្រមុះ ឬមាត់។

**២.៤. លាងសម្អាតដៃ និងការធ្វើអនាម័យខ្លួនប្រាណ**

និយោជកត្រូវ៖

- ផ្តល់សម្ភារ ឬឧបករណ៍លាងសម្អាតដៃឱ្យបានគ្រប់គ្រាន់ នៅគ្រប់ច្រកចេញ-ចូលទីកន្លែងធ្វើការ អគារផលិតកម្ម កន្លែងទទួលទានអាហារ បន្ទប់ទឹក និងបង្គន់អនាម័យ និងកន្លែងចាំបាច់មួយចំនួន ព្រមទាំងត្រូវដាក់សញ្ញាការ ឬចាក់ផ្សាយអំពីវិធានអនាម័យ និងវិធានសុខាភិបាល ដែលអាចឱ្យកម្មករនិយោជិតងាយមើលឃើញ ឬងាយស្តាប់។ សម្ភារ ឬឧបករណ៍លាងសម្អាតដៃរួមមាន ដែលលាងដៃ អាល់កុល សាប៊ូ ទឹកស្អាត មធ្យោបាយជូតសម្អាតដៃ និងឧបករណ៍បាញ់អាល់កុល

- ផ្តល់ជូនកម្មករនិយោជិតនូវពេលវេលាសមស្របណាមួយ ដើម្បីឱ្យពួកគាត់អាចលាងសម្អាតដៃ និងមានដាក់ស្លាកសញ្ញាណែនាំអំពីរបៀបលាងសម្អាតដៃនៅកន្លែងលាងសម្អាតដៃឱ្យបានត្រឹមត្រូវ

- ណែនាំកម្មករនិយោជិតអំពីការរក្សាអនាម័យផ្លូវដង្ហើម ដូចជាការខ្ទប់ ឬបិទមាត់ ច្រមុះ ដោយប្រើប្រាស់ក្រដាសជូតមាត់ កន្សែង ឬកែងដៃ នៅពេលក្អកឬកណ្តាស់ ការលាងសម្អាតដៃជាមួយទឹកសាប៊ូ អាល់កុល ឬដែលសម្លាប់មេរោគ និងបោះចោលក្រដាសដែលបានប្រើរួចឱ្យបានត្រឹមត្រូវ។

## ៣. ក្រោយបញ្ចប់ដំណើរការការងារប្រចាំថ្ងៃ

### ៣.១. ធ្វើអនាម័យ និងបាញ់ថ្នាំសម្លាប់មេរោគនៅកន្លែងធ្វើការ និងកន្លែងប្រើប្រាស់រួមគ្នា

និយោជកត្រូវ៖

- យកចិត្តទុកដាក់សម្អាតអគារផលិតកម្ម អាគារូបដ្ឋាន អាហារដ្ឋាន/កន្លែងហូបបាយ កន្លែងដាក់ភេសជ្ជៈអនាម័យ បន្ទប់ទឹក បង្គន់អនាម័យ ទីធ្លាបរិវេណរោងចក្រ សហគ្រាស និងកន្លែងប្រើប្រាស់រួមផ្សេងទៀត

- រៀបចំបាញ់ថ្នាំសម្លាប់មេរោគយ៉ាងតិច ៣ (បី) ខែម្តង នៅតាមទីតាំង និងបរិវេណសំខាន់ៗ ជាអាទិ៍ អគារផលិតកម្ម ប៉ុស្តិ៍ការងារ អាគារូបដ្ឋាន អាហារដ្ឋាន ឬកន្លែងទទួលទានអាហារ កន្លែងដាក់ភេសជ្ជៈអនាម័យ បន្ទប់ទឹក បង្គន់អនាម័យ អគារស្នាក់នៅរបស់កម្មករនិយោជិត ដែលរៀបចំដោយនិយោជក កន្លែងប្រើប្រាស់រួម និងសម្ភារប្រើប្រាស់ផ្សេងទៀត លើកលែងតែក្នុងករណីមានជំងឺឆ្លងផ្សេងៗក្នុងរោងចក្រ សហគ្រាស និយោជកត្រូវរៀបចំបាញ់ថ្នាំសម្លាប់មេរោគជារៀងរាល់ ១ (មួយ) សប្តាហ៍ម្តង ឬស្របតាមវិធានការសុខាភិបាល

- រៀបចំឱ្យមានការសម្អាតនិងបាញ់ថ្នាំសម្លាប់មេរោគលើទំនិញ កញ្ចប់ទំនិញ កញ្ចប់ប្រៃសណីយ៍ និងសម្ភារផ្សេងៗ ដែលទទួលបានពីខាងក្រៅ

- ណែនាំកម្មករនិយោជិតឱ្យសម្អាតមណ្ឌលការងារ និងសម្ភារប្រើប្រាស់ប្រចាំថ្ងៃរបស់ខ្លួន ដោយប្រើទឹកសាប៊ូ អាល់កុល ឬថ្នាំសម្លាប់មេរោគ នៅពេលមុនចាប់ផ្តើមការងារ និងពេលបញ្ចប់ម៉ោងការងារ

- រៀបចំបិទផ្សាយកាលវិភាគសម្អាតនិងត្រួតពិនិត្យអនាម័យនៅកន្លែងធ្វើការ និងកន្លែងសម្រាប់ផ្តល់ព័ត៌មានរបស់រោងចក្រ សហគ្រាស ដែលអាចឱ្យកម្មករនិយោជិតនិងភ្ញៀវមើលឃើញច្បាស់

- រៀបចំទុកដាក់កាកសំណល់ផ្សេងៗឱ្យបានត្រឹមត្រូវ ដោយដាក់ធុងសំរាមនៅតាមទីតាំងដែលបានកំណត់ និងត្រូវប្រមូលសំរាមចោលជារៀងរាល់ថ្ងៃ ព្រមទាំងលាងសម្អាតធុងសំរាម និងបរិវេណចោលសំរាមជាប្រចាំរាល់ពេលយកសំរាមចេញ

- អនុវត្តវិធានការបង្ការ និងត្រួតពិនិត្យពាក់ព័ន្ធនឹងការប្រើប្រាស់ និងការរក្សាទុកនូវសារធាតុគីមី ជាពិសេសសារធាតុដែលត្រូវប្រើប្រាស់ដើម្បីបាញ់សម្លាប់មេរោគកូវីដ-១៩។

### ៣.២. តាមដានសុខភាពកម្មករនិយោជិត

និយោជកត្រូវ៖

- ចាត់តាំងជនបង្គោលនៅតាមច្រកចេញ-ចូល តាមផ្នែក តាមក្រុម តាមប៉ុស្តិ៍ការងារ និងតាមការិយាល័យសម្រាប់តាមដានសុខភាពរបស់កម្មករនិយោជិតជារៀងរាល់ថ្ងៃ
- បម្រុងទុកឧបករណ៍តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ សម្រាប់ធ្វើតេស្តចំពោះកម្មករនិយោជិតដែលមានរោគសញ្ញា ឬអាការសង្ស័យ
- រៀបចំបន្ទប់ ឬទីតាំងដោយឡែក ដើម្បីត្រៀមបម្រុងធ្វើជាទីតាំងសម្រាប់ធ្វើតេស្ត និងសម្រាប់ដាក់កម្មករនិយោជិតដែលមានរោគសញ្ញា ឬមានអាការសង្ស័យ
- ធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ចំពោះកម្មករនិយោជិតដែលមានរោគសញ្ញា ឬមានអាការសង្ស័យ។ ក្នុងករណីរកឃើញវិជ្ជមានកូវីដ-១៩ ត្រូវដាក់កម្មករនិយោជិតនោះនៅដាច់ដោយឡែក និងត្រូវជូនដំណឹងទៅអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ
- កម្មករនិយោជិតដែលមានជំងឺកូវីដ-១៩ ត្រូវទទួលបានការព្យាបាលតាមកញ្ចប់ ប.ស.ស និងត្រូវទទួលបានការការពារសិទ្ធិការងារស្របតាមច្បាប់ស្តីពីការងារ
- គ្រប់គ្រងកាកសំណល់វេជ្ជសាស្ត្រ ដោយធ្វើការវេចខ្ចប់ឱ្យបានត្រឹមត្រូវ និងយកទៅរក្សាទុក ដុតបំផ្លាញ ឬកប់ចោល និងទុកដាក់ឱ្យបានល្អតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាល។

## ៤. ការគ្រប់គ្រងករណីវិជ្ជមានកូវីដ-១៩

- ក្នុងករណីធ្វើតេស្តរហ័សឃើញវិជ្ជមានកូវីដ-១៩ ម្ចាស់ ឬនាយករោងចក្រ សហគ្រាស ត្រូវ៖
    - ដាក់កម្មករនិយោជិតដែលសង្ស័យវិជ្ជមានកូវីដ-១៩ ក្នុងបន្ទប់ដាច់ដោយឡែកដែលបានបម្រុងទុក
    - រាយការណ៍ និងណែនាំឱ្យកម្មករនិយោជិតដែលសង្ស័យវិជ្ជមានទៅធ្វើតេស្តតាមឧបករណ៍តេស្ត Polymerase Chain Reaction (PCR) ទៅតាមទីតាំង ដែលកំណត់ដោយក្រសួងសុខាភិបាល។
- ក្នុងករណីមានកម្មករនិយោជិតណាម្នាក់មានវិជ្ជមានកូវីដ-១៩ ដែលបញ្ជាក់ដោយលទ្ធផលតេស្ត PCR ម្ចាស់ ឬនាយករោងចក្រ សហគ្រាស ត្រូវអនុវត្តដូចខាងក្រោម៖
    - ទាក់ទងទៅការិយាល័យសុខាភិបាលប្រតិបត្តិខណ្ឌ/ស្រុក ដើម្បីវាយតម្លៃពីកម្រិតជំងឺ ដោយតម្រូវឲ្យផ្តល់ព័ត៌មានលម្អិត ប្រវត្តិធ្វើដំណើរ និងអាការ រួមទាំងការណែនាំអំពីវិធីព្យាបាលតាមវិធានការសុខាភិបាល
    - ជូនដំណឹងបឋមមកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអាជ្ញាធរមូលដ្ឋាន
    - លើកទឹកចិត្តកម្មករនិយោជិតដែលប៉ះពាល់ផ្ទាល់ និងមានអាការសង្ស័យ ឱ្យធ្វើតេស្តរហ័សតាមគោលការណ៍ស្ម័គ្រចិត្ត
    - រៀបចំចាត់ចែងសម្អាតកន្លែងការងារ និងបាញ់ថ្នាំសម្លាប់មេរោគនៅកន្លែងអង្គុយឬប៉ុស្តិ៍ការងារ និងកន្លែងការងារ ដែលមានអ្នកឆ្លង ឬសង្ស័យថាបានប៉ះពាល់ជាមួយអ្នកវិជ្ជមានកូវីដ-១៩
    - រៀបចំបញ្ជីឈ្មោះកម្មករនិយោជិតវិជ្ជមានកូវីដ-១៩ កម្មករនិយោជិតដែលប៉ះពាល់ផ្ទាល់ និងកម្មករនិយោជិតដែលត្រូវធ្វើចត្តាឡីស័ក ធ្វើការតាមដានមើលអ្នកដែលជាប់ពាក់ព័ន្ធ និងចាត់វិធានការគ្រប់គ្រងការរីករាលដាលបន្តក្នុងរោងចក្រ សហគ្រាសឱ្យបានទាន់ពេលវេលា

- ពិនិត្យលទ្ធភាពក្នុងការរៀបចំកន្លែងស្នាក់នៅដាច់ដោយឡែក ឬកន្លែងព្យាបាលដោយឡែក សម្រាប់កម្មករនិយោជិតវិជ្ជមានកូវីដ-១៩
- រៀបចំឱ្យមានសេវាពិគ្រោះយោបល់ផ្លូវចិត្តសម្រាប់កម្មករនិយោជិតវិជ្ជមានកូវីដ-១៩ ប្រសិនបើមានតម្រូវការ
- រាយការណ៍អំពីចំនួនកម្មករនិយោជិតវិជ្ជមានកូវីដ-១៩ ចំនួនកម្មករនិយោជិតដែលប៉ះពាល់ផ្ទាល់ ចំនួនកម្មករនិយោជិតដែលត្រូវធ្វើចត្តាឡីស័ក និងចំនួនកម្មករនិយោជិតដែលជាសះស្បើយពីជំងឺកូវីដ-១៩ មកនាយកដ្ឋានពេទ្យការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ឃ. ការវាយតម្លៃហានិភ័យ

និយោជកត្រូវ៖

- ប្រើប្រាស់បញ្ជីស្វ័យត្រួតពិនិត្យការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដា ដូចមានក្នុងឧបសម្ព័ន្ធទី៣ ជាឧបករណ៍វាយតម្លៃកម្រិតហានិភ័យនៃការឆ្លងជំងឺកូវីដ-១៩។ ក្នុងករណីមានវិជ្ជមានកូវីដ-១៩ លើសពី ១០ភាគរយ ចាត់ទុកថាហានិភ័យខ្ពស់ ត្រូវយកអ្នកជំងឺកូវីដ-១៩ ទៅព្យាបាល និងរៀបចំសំអាតកន្លែងការងារ ឬប៉ុស្តិ៍ការងារដើម្បីដំណើរការផលិតកម្ម/អាជីវកម្ម និងបន្តយកចិត្តទុកដាក់តាមដានសុខភាពរបស់កម្មករនិយោជិត

- តាមដាន និងសិក្សាវាយតម្លៃហានិភ័យការងារជាប្រចាំដោយពិគ្រោះយោបល់ជាមួយនឹងក្រុមការងារសុវត្ថិភាព និងសុខភាពការងារប្រចាំរោងចក្រ សហគ្រាស ដើម្បីពិនិត្យ និងតាមដានអំពីប្រសិទ្ធភាពក្នុងការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដាដែលបានដាក់ចេញ

- កែសម្រួលគោលការណ៍ប្រតិបត្តិស្តង់ដាដែលបានដាក់ចេញស្របទៅតាមស្ថានភាពជាក់ស្តែងនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដើម្បីធានាការអនុវត្តគោលការណ៍នេះប្រកបដោយប្រសិទ្ធភាពក្នុងការចូលរួមបង្ការ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅកន្លែងធ្វើការ

- ត្រូវបំពេញបញ្ជីស្វ័យត្រួតពិនិត្យអំពីការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដា ដោយសហការជាមួយក្រុមការងារសុវត្ថិភាព និងសុខភាពការងារប្រចាំរោងចក្រ សហគ្រាស និងត្រូវរក្សាទុកបញ្ជីស្វ័យត្រួតពិនិត្យនេះសម្រាប់ការត្រួតពិនិត្យរបស់អធិការការងារ និងអធិការពេទ្យការងារ។

## ង. យន្តការអធិការកិច្ច ត្រួតពិនិត្យតាមដាន និងវាយតម្លៃ

អធិការការងារ និងអធិការពេទ្យការងារ មានភារកិច្ចត្រួតពិនិត្យ និងវាយតម្លៃអំពីការអនុវត្តនូវគោលការណ៍ប្រតិបត្តិស្តង់ដា ស្តីពីដំណើរការ និងការគ្រប់គ្រងរោងចក្រ សហគ្រាសតាមគន្លងប្រក្រតីភាពថ្មីក្នុងបរិបទនៃជំងឺកូវីដ-១៩។ ក្នុងករណីដែលរកឃើញថារោងចក្រ សហគ្រាសមិនបានអនុវត្តតាមគោលការណ៍ប្រតិបត្តិស្តង់ដានេះទេ ចាត់ទុកថាបានប្រព្រឹត្តល្មើសនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដែលត្រូវទទួលរងការដាកពិន័យ និងផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ឧបសម្ព័ន្ធទី១៖ គំរូសេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារសុវត្ថិភាព និងសុខភាពការងារប្រចាំរោងចក្រ សហគ្រាស

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**នាមករណ៍៖**...រោងចក្រ សហគ្រាស...
**អាសយដ្ឋាន៖**...............................

**សេចក្តីសម្រេច**
**ស្តីពី**
**ការបង្កើតក្រុមការងារសុវត្ថិភាព និងសុខភាពការងារប្រចាំរោងចក្រ សហគ្រាស......**
..................................................................................................

**យោង៖** - ច្បាប់ស្តីពីការងារ
- គោលការណ៍ប្រតិបត្តិស្តង់ដាស្តីពីដំណើរការ និងការគ្រប់គ្រងរោងចក្រ សហគ្រាសតាមគន្លងប្រក្រតីភាពថ្មីក្នុងបរិបទនៃជំងឺកូវីដ-១៩

**សម្រេច**

**ប្រការ១ .-**

ត្រូវបានបង្កើតក្រុមការងារសុវត្ថិភាព និងសុខភាពការងារដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. លោក/លោកស្រី...(ឈ្មោះ) | ...(មុខតំណែង) | ប្រធាន |
| ២. លោក/លោកស្រី...(ឈ្មោះ) | ...(មុខតំណែង) | អនុប្រធាន |
| ៣. លោក/លោកស្រី...(ឈ្មោះ) | ...(មុខតំណែង) | សមាជិក |
| ៤. លោក/លោកស្រី...(ឈ្មោះ) | ...(មុខតំណែង) | សមាជិក |
| ៥. ........ | | |

**ប្រការ២ .-**

ក្រុមការងារនេះមានភារកិច្ចដូចតទៅ៖

- ផ្សព្វផ្សាយជូនកម្មករនិយោជិតទាំងអស់ឱ្យយល់ជ្រួតជ្រាបពីក្រុមការងារ និងសមាសភាពក្រុមការងារ
- រៀបចំផែនការសកម្មភាពស្តីពីការបង្ការ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩
- រៀបចំបន្ទប់ដាច់ដោយឡែកសម្រាប់អ្នកសង្ស័យវិជ្ជមានជំងឺកូវីដ-១៩ ឬពិគ្រោះយោបល់នៅពេលដែលសង្ស័យឆ្លងមេរោគកូវីដ-១៩ ដោយគ្រូពេទ្យសហគ្រាស (គ្រូពេទ្យ គិលានុបដ្ឋាក និងគិលានុបដ្ឋាយិកា ឬឆ្មប) ឬក្រុមការងារទទួលបន្ទុកសុវត្ថិភាព និងសុខភាពការងារប្រចាំរោងចក្រ សហគ្រាស
- រៀបចំប្រជុំយ៉ាងតិច ១ (មួយ) ដង ក្នុង ១ (មួយ) ខែ។ ក្នុងករណីចាំបាច់ កិច្ចប្រជុំអាចត្រូវបានធ្វើឡើងជាបន្ទាន់ ដើម្បីដោះស្រាយបញ្ហា ប្រសិនបើមានហេតុការណ៍កើតឡើងនៅផ្នែកណាមួយពាក់ព័ន្ធទៅនឹងការអនុវត្តវិធានសុវត្ថិភាព និងសុខភាពការងារ
- ផ្សព្វផ្សាយអំពីផែនការសកម្មភាព និងការអនុវត្តនូវវិធានការនានាជូនដល់កម្មករនិយោជិត ដើម្បីចូលរួមបង្ការ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងរោងចក្រ សហគ្រាស

- រៀបចំឱ្យមានការបណ្តុះបណ្តាលដល់ក្រុមការងារសុវត្ថិភាព និងសុខភាពការងារនិងកម្មករនិយោជិត អំពីវិធានសុវត្ថិភាព និងសុខភាពការងារនៅក្នុងរោងចក្រ សហគ្រាសរបស់ខ្លួន ដោយសហការជាមួយអធិការពេទ្យការងារ
- ពិនិត្យតាមដាន និងវាយតម្លៃអំពីការអនុវត្តលក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារនៅក្នុងរោងចក្រ សហគ្រាសដោយរៀបចំជាតារាងកាលវិភាគឱ្យបានត្រឹមត្រូវ
- កែលម្អលក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារ ប្រសិនបើរកឃើញថាអនុវត្តមិនបានត្រឹមត្រូវតាមច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ ឬរកឃើញថាអាចមានហានិភ័យបង្កឱ្យមានគ្រោះថ្នាក់ដល់កម្មករនិយោជិត
- សិក្សាវាយតម្លៃហានិភ័យ និងរៀបចំវិធានការផ្សេងៗ សម្រាប់ការបើកដំណើរការឡើងវិញនៃរោងចក្រ សហគ្រាស ដែលត្រូវបានផ្អាកដោយវិធានការរដ្ឋបាល ឬដោយការព្យួរសកម្មភាពអាជីវកម្មរបស់ខ្លួន
- អាចលើកសំណើពាក់ព័ន្ធនឹងលក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារមកនាយកដ្ឋានពេទ្យការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីស្នើសុំយោបល់ និងជួយដោះស្រាយ
- រៀបចំរបាយការណ៍វាយតម្លៃអំពីស្ថានភាពសុវត្ថិភាព និងសុខភាពការងារនៃកម្មករនិយោជិតនៅក្នុងរោងចក្រ សហគ្រាស ប្រចាំខែ ជូននិយោជកទទួលស្គាល់ និងបញ្ជូនមកក្រុមការងារទទួលរបាយការណ៍នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់ប្រធានក្រុមការងារ។

**ប្រការ៣ .-**

ប្រធានក្រុមការងារ មានសិទ្ធិក្នុងការសម្រេចចិត្តនៅក្នុងរោងចក្រ សហគ្រាស និងត្រូវកោះប្រជុំកំណត់អំពីបទបញ្ជាផ្ទៃក្នុង ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តការងាររបស់ក្រុមការងារ។

បទបញ្ជាផ្ទៃក្នុង ត្រូវបានកំណត់អំពីរបៀបរបប និងរបៀបវារៈនៃកិច្ចប្រជុំ នីតិវិធីនៃការពិភាក្សា និងការអនុម័ត ជាដើម។

**ប្រការ៤ .-**

គណៈគ្រប់គ្រងរោងចក្រ សហគ្រាស និយោជក តំណាងកម្មករនិយោជិត និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

................ថ្ងៃទី................ ខែ................ ឆ្នាំ២០២...

...ហត្ថលេខា និងត្រា

ម្ចាស់ ឬនាយករោងចក្រ សហគ្រាស

**ចម្លងជូន** :
-នាយកដ្ឋានពេទ្យការងារ
"ដើម្បីជូនជ្រាប"
- ដូចប្រការ៤ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី២៖ គំរូរបាយការណ៍វាយតម្លៃប្រចាំខែស្តីពីស្ថានភាពសុវត្ថិភាព និងសុខភាពការងារនៃកម្មករនិយោជិតនៅក្នុងរោងចក្រ សហគ្រាស

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## របាយការណ៍វាយតម្លៃប្រចាំខែ
## ស្តីពី
## ស្ថានភាពសុវត្ថិភាព និងសុខភាពការងារនៃកម្មករនិយោជិតនៅក្នុងរោងចក្រ សហគ្រាស

### ក. ព័ត៌មានទូទៅ

- នាមករណ៍រោងចក្រ សហគ្រាសជាភាសាខ្មែរ៖..........................................................................ជាអក្សរឡាតាំង៖..........................................................................
- អាសយដ្ឋាន៖..........................................................................................................លេខទូរស័ព្ទ៖...........................អ៊ីម៉ែល៖...........................
- ឈ្មោះនាយក៖...............................................សញ្ជាតិ៖ ...........................ឈ្មោះប្រធានរដ្ឋបាល៖.......................................លេខទូរស័ព្ទ៖........................
- សកម្មភាពសេដ្ឋកិច្ច៖..........................................................................ជាសមាជិក: ☐ CAMFEBA ☐ GMAC ☐ CFA ☐ ILO ☐ ផ្សេងៗ៖................

### ខ. ចំនួនកម្មករនិយោជិតសរុប៖.........................នាក់ (ស្រី៖..................នាក់) ក្នុងនោះ បរទេសសរុប៖.................នាក់ (ស្រី៖...................នាក់)

### គ. តារាងរាយការណ៍ករណីជំងឺកូវីដ-១៩ និងការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩នៅក្នុងរោងចក្រ សហគ្រាស

| ល.រ | ចំនួនកម្មករនិយោជិតដែលបានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ | | | | ចំនួនកម្មករនិយោជិតមានរោគសញ្ញាសង្ស័យ និងធ្វើតេស្តស្វែងរកមេរោគកូវីដ-១៩ | | | ប្រភេទនៃការធ្វើតេស្តរកមេរោគកូវីដ-១៩ | | ចំនួនកម្មករនិយោជិតដែលបានបញ្ជូន និងរាយការណ៍ករណីជំងឺកូវីដ-១៩ | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ដូសទី១ | ដូសទី២ ឬ គ្រប់ដូស | ដូសទី៣ ឬដូសជម្រុញ | សរុប | អ្នកវិជ្ជមាន | អ្នកប៉ះពាល់ផ្ទាល់ | Rapid test | PCR | ចត្តាឡីស័ក | ព្យាបាល | ជាសះស្បើយ | មរណភាព | |
| ១ | ..នាក់(ស្រី.. នាក់) | ..នាក់(ស្រី.. នាក់) | ..នាក់(ស្រី.. នាក់) | ..នាក់(ស្រី.. នាក់) | ..នាក់(ស្រី.. នាក់) | ..នាក់(ស្រី.. នាក់) | ..នាក់(ស្រី.. នាក់) | ..នាក់(ស្រី.. នាក់) | ..នាក់(ស្រី.. នាក់) | ..នាក់(ស្រី.. នាក់) | ..នាក់(ស្រី ..នាក់) | ..នាក់(ស្រី.. នាក់) | ..នាក់(ស្រី.. នាក់) | |

................ថ្ងៃទី................ ខែ................ ឆ្នាំ២០២...
...ហត្ថលេខា និងឈ្មោះប្រធាន
ក្រុមការងារសុវត្ថិភាព និងសុខភាពការងារប្រចាំរោងចក្រ សហគ្រាស...

**បានឃើញ និងឯកភាព**
................ថ្ងៃទី................ ខែ................ ឆ្នាំ២០២...
...ហត្ថលេខា និងត្រា
ម្ចាស់ ឬនាយក/តំណាងរោងចក្រ សហគ្រាស...

ឧបសម្ព័ន្ធទី៣៖ បញ្ជីស្ទង់ត្រួតពិនិត្យអំពីសកម្មភាពពង្រឹងលក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារនៅតាមរោងចក្រ សហគ្រាស

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# បញ្ជីស្ទង់ត្រួតពិនិត្យ
## អំពីសកម្មភាពពង្រឹងលក្ខខណ្ឌសុវត្ថិភាព និងសុខភាពការងារនៅតាមរោងចក្រ សហគ្រាស

នាមករណ៍រោងចក្រ សហគ្រាស៖..........................................................................................សកម្មភាពអាជីវកម្ម៖.....................................................
អាសយដ្ឋាន៖ផ្ទះ/អគារលេខ...........ផ្លូវ............ភូមិ.........................ឃុំ/សង្កាត់.................................ស្រុក/ខណ្ឌ............................រាជធានី/ខេត្ត............................
ចំនួនកម្មករនិយោជិតសរុប៖ចំនួន.............................នាក់ ក្នុងនោះស្រីចំនួន.....................នាក់ ក្នុងនោះមានបរទេសចំនួន.....................នាក់ ស្រីចំនួន........................នាក់
ឈ្មោះម្ចាស់ឬតំណាង៖...............................................លេខទូរស័ព្ទ៖.................................ឈ្មោះរដ្ឋបាល៖.................................លេខទូរស័ព្ទ៖.............................

| ល.រ | សកម្មភាព | លទ្ធផលត្រួតពិនិត្យ | កំណត់សម្គាល់ |
|---|---|---|---|
| **១. ក្រុមការងារសុវត្ថិភាព និងសុខភាពការងារប្រចាំរោងចក្រ សហគ្រាស** | | | |
| ១.១. ការបង្កើតក្រុមការងារសុវត្ថិភាព និងសុខភាពការងារប្រចាំរោងចក្រ សហគ្រាស | | ☐ មាន ☐ គ្មាន | |
| ១.២. ការធ្វើរបាយការណ៍ប្រចាំខែ ដើម្បីវាយតម្លៃអំពីស្ថានភាពសុវត្ថិភាព និងសុខភាពការងារនៃកម្មករនិយោជិតនៅក្នុងរោងចក្រ សហគ្រាស | | ☐ មាន ☐ គ្មាន | |
| **២. ការអនុវត្តវិធានការរបស់រាជរដ្ឋាភិបាល " ៣ការពារ ៣កុំ "** | | | |
| ២.១. ផ្តល់ម៉ាស់ជូនកម្មករនិយោជិតដោយឥតគិតថ្លៃ និងធ្វើការណែនាំពីរបៀបប្រើប្រាស់ម៉ាស់ឱ្យបានត្រឹមត្រូវ និងជាប់ជាប្រចាំនៅពេលបំពេញការងារ និងពេលធ្វើដំណើរទៅផ្ទះ និងកន្លែងធ្វើការ | | ☐ មាន ☐ គ្មាន | |
| ២.២. ផ្តល់សម្ភារ ឬឧបករណ៍លាងសម្អាតដៃ ឧបករណ៍បាញ់អាល់កុលនៅគ្រប់ច្រកចេញ-ចូលទីកន្លែងធ្វើការ អគារផលិតកម្ម កន្លែងទទួលទានអាហារ បន្ទប់ទឹក និងបង្គន់អនាម័យ និងផ្តល់ជែលលាងដៃ អាល់កុល សាប៊ូ ទឹកស្អាត មធ្យោបាយជូតសម្អាតដៃ និងដាក់ស្លាកសញ្ញា ឬចាក់ផ្សាយអំពីវិធានអនាម័យ និងវិធានសុខាភិបាល ដែលអាចឱ្យកម្មករនិយោជិតងាយមើលឃើញ ឬងាយស្តាប់ | | ☐ មាន ☐ គ្មាន | |

| ល.រ | សកម្មភាព | លទ្ធផលត្រួតពិនិត្យ | កំណត់សម្គាល់ |
|---|---|---|---|
| ២.៣. រៀបចំដាក់របាំងខណ្ឌ ឬប្រើប្រាស់មធ្យោបាយសមស្របផ្សេងៗ ក្នុងពេលប្រាស្រ័យទាក់ទងជាមួយសាធារណជន ឬពេលហូបបាយជុំគ្នា ក្នុងករណីដែលមិនអាចរក្សាគម្លាតសុវត្ថិភាព | | ☐ មាន ☐ គ្មាន | |
| ២.៤. បើកដំណើរការប្រព័ន្ធបញ្ចេញនិងបញ្ចូលខ្យល់ក្នុងអគារផលិតកម្ម ក្នុងរយៈពេលយ៉ាងហោចណាស់ ៣០ (សាមសិប) នាទី មុនពេលដំណើរការផលិតកម្ម | | ☐ មាន ☐ គ្មាន | |
| ២.៥. មានថែទាំ និងជួសជុលប្រព័ន្ធបញ្ចេញនិងបញ្ចូលខ្យល់ជាទៀងទាត់ | | ☐ មាន ☐ គ្មាន | |
| ២.៦. ណែនាំដល់កម្មករនិយោជិតឱ្យជៀសវាងឬកាត់បន្ថយការប៉ះពាល់គ្នាដោយផ្ទាល់នៅពេលប្រាស្រ័យទាក់ទងគ្នា ដោយត្រូវរក្សាគម្លាតសុវត្ថិភាពសមស្រប | | ☐ មាន ☐ គ្មាន | |
| ២.៧. ណែនាំដល់កម្មករនិយោជិតឱ្យពាក់ម៉ាស់ជាប្រចាំ លាងសម្អាតដៃឱ្យបានស្អាត កាត់បន្ថយជាអតិបរមាក្នុងការយកដៃទៅប៉ះភ្នែក ច្រមុះ ឬមាត់ | | ☐ មាន ☐ គ្មាន | |
| **៣. ការអនុវត្តវិធានសុវត្ថិភាព និងសុខភាពការងារ និងវិធានការសុខាភិបាលនៅក្នុងរោងចក្រ សហគ្រាស** | | | |
| ៣.១. ណែនាំ អប់រំ និងលើកទឹកចិត្តឱ្យកម្មករនិយោជិតចូលរួមចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ឱ្យបានគ្រប់ៗគ្នា | | ☐ មាន ☐ គ្មាន | |
| ៣.២. រៀបចំធ្វើការសម្អាតឱ្យមានអនាម័យជានិច្ចនូវអគារផលិតកម្ម អាគារបដ្ឋាន អាហារដ្ឋាន/កន្លែងហូបបាយ កន្លែងដាក់ភេសជ្ជៈអនាម័យ បន្ទប់ទឹក បង្គន់អនាសម័យ ទីធ្លាបរិវេណរោងចក្រ សហគ្រាស និងកន្លែងប្រើប្រាស់រួមផ្សេងទៀត | | ☐ មាន ☐ គ្មាន | |
| ៣.៣. រៀបចំជាស្លាកសញ្ញាអប់រំសុខភាពស្តីពីវិធានការបង្ការ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងត្រូវដាក់ ឬបិតផ្សព្វផ្សាយនៅកន្លែងធ្វើការ ដែលអាចឱ្យកម្មករនិយោជិតមើលឃើញច្បាស់ | | ☐ មាន ☐ គ្មាន | |
| ៣.៤. ផ្សព្វផ្សាយលើកកម្ពស់ឱ្យមានការយល់ដឹងអំពីសារអប់រំផ្សេងៗ ដូចជា វិធានការ "៣ការពារ និង៣កុំ" | | ☐ មាន ☐ គ្មាន | |
| ៣.៥. ចាត់តាំងជនបង្គោលនៅតាមច្រកចេញ-ចូល តាមផ្នែក តាមក្រុម តាមប៉ុស្តិ៍ការងារ និងតាមការិយាល័យសម្រាប់តាមដានសុខភាពរបស់កម្មករនិយោជិតជារៀងរាល់ថ្ងៃ | | ☐ មាន ☐ គ្មាន | |
| ៣.៦. បម្រុងទុកឧបករណ៍តេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ សម្រាប់ធ្វើតេស្តចំពោះកម្មករនិយោជិតដែលមានរោគសញ្ញា ឬអាការសង្ស័យ | | ☐ មាន ☐ គ្មាន | |
| ៣.៧. រៀបចំបន្ទប់ ឬទីតាំងដោយឡែក ដើម្បីត្រៀមបម្រុងធ្វើជាទីតាំងសម្រាប់ធ្វើតេស្ត និងសម្រាប់ដាក់កម្មករនិយោជិតដែលមានរោគសញ្ញា ឬមានអាការសង្ស័យ | | ☐ ត្រឹមត្រូវ ☐ មិនត្រឹមត្រូវ | |
| ៣.៨. ធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ចំពោះកម្មករនិយោជិតដែលមានរោគសញ្ញា ឬមានអាការសង្ស័យ | | ☐ មាន ☐ គ្មាន | |

| ល.រ | សកម្មភាព | លទ្ធផលត្រួតពិនិត្យ | | កំណត់សម្គាល់ |
|---|---|---|---|---|
| **៤. ការគ្រប់គ្រងករណីវិជ្ជមានកូវីដ-១៩ ក្នុងករណីធ្វើតេស្តរហ័សឃើញវិជ្ជមានកូវីដ-១៩** | | | | |
| | ៤.១. ដាក់កម្មករនិយោជិតដែលសង្ស័យវិជ្ជមានកូវីដ-១៩ នៅក្នុងបន្ទប់ដាច់ដោយឡែក ដែលបានបម្រុងទុក | ☐ មាន | ☐ គ្មាន | |
| | ៤.២. រាយការណ៍ និងណែនាំឱ្យកម្មករនិយោជិតដែលសង្ស័យវិជ្ជមានទៅធ្វើតេស្ត PCR ទៅតាមទីតាំង ដែលកំណត់ដោយក្រសួងសុខាភិបាល | ☐ មាន | ☐ គ្មាន | |
| **៥. ការគ្រប់គ្រងករណីវិជ្ជមានកូវីដ-១៩ ក្នុងករណីមានកម្មករនិយោជិតណាម្នាក់មានវិជ្ជមានកូវីដ-១៩ ដែលបញ្ជាក់ដោយលទ្ធផល** PCR | | | | |
| | ៥.១. ទំនាក់ទំនងទៅការិយាល័យសុខាភិបាលប្រតិបត្តិខណ្ឌ/ស្រុក ដើម្បីវាយតម្លៃពីកម្រិតជំងឺ និងចាត់ចែងណែនាំអំពីវិធីព្យាបាលតាមវិធានការសុខាភិបាល | ☐ មាន | ☐ គ្មាន | |
| | ៥.២. ជូនដំណឹងបឋមមកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងអាជ្ញាធរមូលដ្ឋាន | ☐ មាន | ☐ គ្មាន | |
| | ៥.៣. លើកទឹកចិត្តកម្មករនិយោជិតដែលប៉ះពាល់ផ្ទាល់ និងមានអាការសង្ស័យ ឱ្យធ្វើតេស្តរហ័សតាមគោលការណ៍ស្ម័គ្រចិត្ត | ☐ មាន | ☐ គ្មាន | |
| | ៥.៤. ចាត់ចែងបាញ់ថ្នាំសម្លាប់មេរោគនៅកន្លែងអង្គុយឬប៉ុស្តិ៍ការងារ និងកន្លែងធ្វើការ ដែលមានកម្មករនិយោជិតវិជ្ជមានកូវីដ-១៩ | ☐ មាន | ☐ គ្មាន | |
| | ៥.៥. រៀបចំបញ្ជីឈ្មោះកម្មករនិយោជិតវិជ្ជមានកូវីដ-១៩ កម្មករនិយោជិតដែលប៉ះពាល់ផ្ទាល់ និងកម្មករនិយោជិតដែលត្រូវធ្វើចត្តាឡីស័ក និងចាត់វិធានការគ្រប់គ្រងការរីករាលដាលបន្តក្នុងរោងចក្រ សហគ្រាស | ☐ មាន | ☐ គ្មាន | |
| | ៥.៦. រាយការណ៍អំពីចំនួនកម្មករនិយោជិតវិជ្ជមានកូវីដ-១៩ ចំនួនកម្មករនិយោជិតដែលប៉ះពាល់ផ្ទាល់ ចំនួនកម្មករនិយោជិតដែលត្រូវធ្វើចត្តាឡីស័ក និងចំនួនកម្មករនិយោជិតដែលជាសះស្បើយពីជំងឺកូវីដ-១៩ មកនាយកដ្ឋានពេទ្យការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ☐ មាន | ☐ គ្មាន | |